# គម្រោងវិនិយោគក្នុង ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

**គម្រោងវិនិយោគ**
**៦៣០** (២៤៣ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**១០** ប៊ីលាន ដុល្លារអាមេរិក

**បង្កើតការងារ**
**~៤៣៨ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)



**៤៣៦ លាន** កសិកម្ម និងកសិ-ឧស្សាហកម្ម

**៣,៨ ប៊ីលាន** វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**១៧៥ លាន** ទេសចរណ៍

**៥,៦ ប៊ីលាន** វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៥៤,២៥% |
| 2. កម្ពុជា | ៣១,២៧% |
| 3. សិង្ហបុរី | ៥,៩៩% |
| 4. វៀតណាម | ៤,១០% |
| 5. កោះ British Virgin | ១,៧៤% |
| 6. ចក្រភពអង់គ្លេស | ០,៤៩% |
| 7. សហរដ្ឋអាមេរិក | ០,៤៤% |
| 8. កោះ Cayman | ០,៤០% |
| 9. កោះ Samoa | ០,៣៧% |
| 10. Bermuda | ០,២៦% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត




**កំណត់សម្គាល់**

- # ចំនួនគម្រោង
- ៧១+
- ៤១-៧០
- ២១-៤០
- ១-២០
- មិនមាន

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# INVESTMENT PROJECTS IN 2025

Approved by the Cambodian Investment Board,
the Council for the Development of Cambodia

**Investment Projects**
**630**
(243 projects in SEZs)

**Investment Capital**
**10**
Billion USD

Estimated
**~438K**
**Jobs Created**

## INVESTMENT BY SECTORS (in USD)




## LEADING SOURCES OF INVESTMENT

| Country | Share |
|---|---|
| 1. China | 54.25% |
| 2. Cambodia | 31.27% |
| 3. Singapore | 5.99% |
| 4. Vietnam | 4.10% |
| 5. British Virgin Islands | 1.74% |
| 6. The United Kingdom | 0.49% |
| 7. The United States | 0.44% |
| 8. Cayman Islands | 0.40% |
| 9. Samoa Islands | 0.37% |
| 10. Bermuda | 0.26% |

## GEOGRAPHICAL DISTRIBUTION OF INVESTMENT PROJECTS



រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

*ថ្ងៃចន្ទ ២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៦៣០ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ១០ប៊ីលានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០២៥

ក្នុងឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.វ.ក. នៃ ក.អ.ក.) បានចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន ៦៣០ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ១០ប៊ីលានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ ៤៣៨៣ាន់កន្លែង។ គម្រោងវិនិយោគដែលមានទីតាំស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៣៨៧ និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ២៤៣។ ជាការកត់សម្គាល់ ការចុះបញ្ជីគម្រោងវិនិយោគមានការកើនឡើងចំនួន២១៦ ស្មើនឹងប្រមាណ ៥២% ខណៈទំហំទុនវិនិយោគមានការកើនឡើងប្រមាណ ៣ប៊ីលានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ ៤៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ ដែល គ.វ.ក. នៃ ក.អ.ក.បានចុះបញ្ជីគម្រោងវិនិយោគចំនួន ៤១៤ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៦,៩ប៊ីលានដុល្លារអាម៉េរិក។ សមិទ្ធផលនេះជាការបង្កើតកំណត់ត្រាថ្មីមួយទៀត ដែលកាលពីឆ្នាំ២០២៤ គ.វ.ក. នៃ ក.អ.ក.បានបង្កើតកំណត់ត្រាថ្មីនៃការចុះបញ្ជីគម្រោងវិនិយោគម្តងរួចហើយ។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំឆ្នាំរួមមាន៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

**កសិកម្ម និង កសិ-ឧស្សាហកម្ម**

**គម្រោងពង្រីកផលិតកម្មកសិដ្ឋានដាំដំណាំហូបផ្លែ និងរោងចក្រកែច្នៃ**
- ទីតាំង៖ ខេត្តរតនគិរី
- ទុនវិនិយោគប្រមាណ៖ ២២៦លានដុល្លារអាម៉េរិក
- បង្កើតការងារប្រមាណ៖ ៨,៥៣ាន់កន្លែង។

**គម្រោងពង្រីកផលិតកម្មកសិដ្ឋានចិញ្ចឹមគោពូជ និងគោសាច់ខ្នាតធំ**
- ទីតាំង៖ ខេត្តក្រចេះ
- ទុនវិនិយោគប្រមាណ៖ ១២០លានដុល្លារអាម៉េរិក
- បង្កើតការងារប្រមាណ៖ ៩០០កន្លែង។

គម្រោងវិនិយោគបង្កើតរោងចក្រកែច្នៃកសិផល និងផលិតចំណីអាហារពីកសិផល

- ទីតាំង៖ ខេត្តកំពង់ស្ពឺ
- ទុនវិនិយោគប្រមាណ៖ ៣១លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ៦៧៥កន្លែង។

គម្រោងបង្កើតរោងចក្រកែច្នៃផ្លែឈើ

- ទីតាំង៖ ខេត្តបាត់ដំបង
- ទុនវិនិយោគចំនួន៖ ២៧លានដុល្លារអាមេរិក
- បង្កើតការងារប្រមាណ៖ ១ពាន់កន្លែង។

**ឧស្សាហកម្ម**

គម្រោងវិនិយោគបង្កើតរោងចក្រផលិតស៊ីម៉ងត៍

- ទីតាំង៖ ខេត្តក្រចេះ
- ទុនវិនិយោគចំនួន៖ ២៨៦លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ៤២០កន្លែង។

គម្រោងវិនិយោគអាជីវកម្មរ៉ែដែក

- ទីតាំង៖ ខេត្តកំពត
- ទុនវិនិយោគចំនួន៖ ១៦៨លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ៣៧៣កន្លែង។

គម្រោងវិនិយោគបង្កើតរោងចក្រផលិតក្រណាត់ និងអំបោះគ្រប់ប្រភេទ

- ទីតាំង៖ ខេត្តកណ្ដាល
- ទុនវិនិយោគប្រមាណ៖ ៥០លានដុល្លារអាមេរិក
- បង្កើតការងារប្រមាណ៖ ១,៨ពាន់កន្លែង។

គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំដំឡើងរថយន្ត

- ទីតាំង៖ ខេត្តកំពង់ឆ្នាំង
- ទុនវិនិយោគប្រមាណ៖ ១៩លានដុល្លារអាមេរិក
- បង្កើតការងារប្រមាណ៖ ១,២ពាន់កន្លែង។

**ទេសចរណ៍**

គម្រោងវិនិយោគសាងសង់ និងអាជីវកម្មសណ្ឋាគារផ្កាយ៥ ចំនួន២២៧បន្ទប់

- ទីតាំង៖ រាជធានីភ្នំពេញ
- ទុនវិនិយោគប្រមាណ៖ ៨៥លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ២៣០កន្លែង។

គម្រោងវិនិយោគសាងសង់ និងធ្វើអាជីវកម្មសណ្ឋាគារផ្កាយ៥ ចំនួន២៨០បន្ទប់

- ទីតាំង៖ ខេត្តស្វាយរៀង
- ទុនវិនិយោគប្រមាណ៖ ៦២លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ៤៩៥កន្លែង។

គម្រោងវិនិយោគបង្កើតរមណីយដ្ឋានទេសចរណ៍សេវាកម្មចម្រុះ

- ទីតាំង៖ ខេត្តស្ទឹងត្រែង
- ទុនវិនិយោគប្រមាណ៖ ២០លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ១៤២កន្លែង។

| | |
|---|---|
| ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ | **គម្រោងវិនិយោគសាងសង់ និងប្រតិបត្តិការព្រែកជីកហ្វូណនតេជោ**<br>- ទីតាំង៖ ខេត្តកណ្ដាល តាកែវ កំពត និងកែប<br>- ទុនវិនិយោគប្រមាណ៖ ១,៧ប៊ីលានដុល្លារអាម៉េរិក<br>- បង្កើតការងារប្រមាណ៖ ៣,២៣៨កន្លែង។<br>**គម្រោងវិនិយោគសាងសង់វារីអគ្គិសនី អានុភាព១៥០មេហ្គាវ៉ាត់**<br>- ទីតាំង៖ ខេត្តកោះកុង និងពោធិ៍សាត់<br>- ទុនវិនិយោគប្រមាណ៖ ៤៤២លានដុល្លារអាម៉េរិក<br>- បង្កើតការងារប្រមាណ៖ ២២០កន្លែង។<br>**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ ចំនួន ៤គម្រោង អានុភាព៤៥០មេហ្គាវ៉ាត់**<br>- ទីតាំង៖ ខេត្តកំពង់ឆ្នាំង បាត់ដំបង និងពោធិ៍សាត់<br>- ទុនវិនិយោគប្រមាណ៖ ៣០៩លានដុល្លារអាម៉េរិក<br>- បង្កើតការងារប្រមាណ៖ ១៣៥កន្លែង។<br>**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ចំនួន ២គម្រោង អានុភាព ៣០០មេហ្គាវ៉ាត់**<br>- ទីតាំង៖ ខេត្តមណ្ឌលគិរី<br>- ទុនវិនិយោគប្រមាណ៖ ៤៣០លានដុល្លារអាម៉េរិក<br>- បង្កើតការងារចំនួន៖ ១៦៩កន្លែង។<br>**គម្រោងវិនិយោគបង្កើតមន្ទីរពេទ្យចំនួន២២១គ្រែ**<br>- ទីតាំង៖ រាជធានីភ្នំពេញ<br>- ទុនវិនិយោគប្រមាណ៖ ៧៦លានដុល្លារអាម៉េរិក<br>- បង្កើតការងារចំនួន៖ ៧៤១កន្លែង។<br>**គម្រោងវិនិយោគបង្កើតផែស្ងួត**<br>- ទីតាំង៖ ខេត្តព្រៃវែង<br>- ទុនវិនិយោគប្រមាណ៖ ២០លានដុល្លារអាម៉េរិក<br>- បង្កើតការងារចំនួន៖ ៦៦កន្លែង។ |

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតសំបកកង់រថយន្តចំនួន ២គម្រោង**<br>- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស អាយ អេស អាយ ស្ថិតនៅខេត្តព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេស ស៊ីន បារិត ស្ថិតនៅខេត្តស្វាយរៀង<br>- ទុនវិនិយោគ៖ ៤៣៧លានដុល្លារអាម៉េរិក<br>- បង្កើតការងារ៖ ៣.៤០០កន្លែង។<br>**គម្រោងពង្រីកផលិតកម្មផលិតសំបកកង់រថយន្តចំនួន២គម្រោង**<br>- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ស៊ីន បារិត ស្ថិតនៅខេត្តស្វាយរៀង និងតំបន់សេដ្ឋកិច្ចពិសេស ឈី លូ ជាន ព្ ចាយ ស្ថិតនៅខេត្តស្វាយរៀង<br>- ទុនវិនិយោគ៖ ៣៣៧លានដុល្លារអាម៉េរិក។ |

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតឧបករណ៍បរិក្ខារពេទ្យ និងស្រោមដៃគ្រប់ប្រភេទ**

- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ឈីលូ ជាន ពុ ចាយ ស្ថិតនៅខេត្តស្វាយរៀង
- ទុនវិនិយោគប្រមាណ៖ ២៧៤លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ៥១៧កន្លែង។

**គម្រោងពង្រីកបន្ថែមទំហំផ្ទៃដីអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស**

- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន ស្ថិតនៅខេត្តស្វាយរៀង
- ទុនវិនិយោគប្រមាណ៖ ៩១លានដុល្លារអាមេរិក។

**គម្រោងពង្រីកបន្ថែមទុនវិនិយោគអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស**

- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស កោះកុង ចេជាង ស្ថិតនៅខេត្តកោះកុង
- ទុនវិនិយោគចំនួន៖ ៥០លានដុល្លារអាមេរិក។

**គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំដំឡើងយានយន្ត**

- ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
- ទុនវិនិយោគប្រមាណ៖ ៣២លានដុល្លារអាមេរិក
- បង្កើតការងារចំនួន៖ ២០៥កន្លែង។

សូមជម្រាបជូនផងដែរថា បន្ថែមពីលើគម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីនៅ គ.វ.ក. នៃ ក.អ.ក. នៅក្នុងឆ្នាំ២០២៥នេះ អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត បានសម្រេចចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន ២២៨គម្រោង ដែលមានទុនវិនិយោគសរុបប្រមាណ ៧៦៣លានដុល្លារអាមេរិក និងអាចបង្កើតការងារបានប្រមាណ១០៦៣ពាន់កន្លែង។




| | កំពង់ស្ពឺ | កណ្ដាល | តាកែវ | ភ្នំពេញ | ត្បូងឃ្មុំ | កំពង់ធំ | ព្រះសីហនុ | ស្វាយរៀង |
|---|---|---|---|---|---|---|---|---|
| ទំហំទុនវិនិយោគ | 365 | 166 | 155 | 61 | 8 | 5 | 2 | 2 |
| ចំនួនគម្រោង | 105 | 50 | 46 | 22 | 2 | 1 | 1 | 1 |

គម្រោងវិនិយោគទាំង ២២៨ នេះសុទ្ធសឹងតែជាការវិនិយោគក្នុងវិស័យឧស្សាហកម្ម និងមានប្រភពទុនវិនិយោគមកពីប្រទេសចិនប្រមាណ ៧២៨លានដុល្លារអាមេរិក, ក្នុងស្រុកប្រមាណ ២២,៦លានដុល្លារអាមេរិក, អូស្ត្រាលីប្រមាណ ៥លានដុល្លារអាមេរិក, សិង្ហបុរីប្រមាណ ៣,៤លានដុល្លារអាមេរិក, សហរដ្ឋអាមេរិកប្រមាណ ១,៥លានដុល្លារអាមេរិក, ម៉ាឡេស៊ីប្រមាណ ១លានដុល្លារ អាមេរិក និងជប៉ុនប្រមាណ ៦១ម៉ឺនដុល្លារអាមេរិក។